១១ មិថុនា ២០០៩

# ការប្រកាសទទួលយកសំណើសង្ខេបរបស់មូលនិធិភាពជាដៃគូសំរាប់ប្រពន្ធ័អេកូស៊ីស្ទែមដែលទទួលរងការគំរាមកំហែង (CEPF) ប្រចាំតំបន់ឥណ្ឌូចិន

អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំតំបន់ឥណ្ឌូចិន ក្នុងតួនាទីរបស់ខ្លួនជាក្រុមការងារថ្នាក់តំបន់សំរាប់មូលនិធិភាពជាដៃគូសំរាប់ប្រពន្ធ័អេកូស៊ីស្ទែមដែលទទួលរងការគំរាមកំហែង (CEPF) ក្នុងតំបន់ឥណ្ឌូ-ភូមា សូមប្រកាសទទួលយកសំណើសង្ខេប (Letters of Inquiry-LoIs) ពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ និងអង្គការសង្គមស៊ីវិលដទៃផ្សេងៗទៀត ។

មូលនិធិភាពជាដៃគូសំរាប់ប្រពន្ធ័អេកូស៊ីស្ទែមដែលទទួលរងការគំរាមកំហែង (CEPF) ត្រូវបានបង្កើតឡើងដើម្បីការពារតំបន់ដែលសំបូរបែបដោយជីវចម្រុះ និងតំបន់ដែលទទួលរងការគំរាមកំហែងបំផុតរបស់ផែនដីដែលត្រូវបានគេស្គាល់ថាជាតំបន់ជីវចម្រុះហតស្ពត (Biodiversity hotspots) ។ CEPF គឺជាការផ្តួចផ្តើមបង្កើតរួមគ្នាមួយរវាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD), អង្គការអភិរក្សអន្តរជាតិ (CI), មូលនិធិបរិស្ថានពិភពលោក (GEF), រដ្ឋាភិបាលជប៉ុន, មូលនិធិម៉ាកាធ័រ (John D. and Catherine T. MacArthur) និង ធនាគារពិភពលោក ។ ទិសដៅសំខាន់គឺដើម្បីធានាឱ្យសង្គមស៊ីវិលបានចូលរួមក្នុងការអភិរក្សជីវចម្រុះ ។

នេះជាការប្រកាសទទួលយកសំណើសង្ខេបជាលើកទីពីរធ្វើដោយអង្គកាជីវិតសត្វស្លាប និងស៊ីអ៊ីភីអេហ្វក្នុងតំបន់ឥណ្ឌូចិន ។ កាលបរិច្ឆេទកំនត់ចុងក្រោយនៃការទទួលយកសំណើសង្ខេបគឺនៅវេលាម៉ោង **០៥:៣០នាទីល្ងាច (ម៉ោងនៅភ្នំពេញ និងហាណូយ) ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩** ប៉ុន្តែលោក-លោកស្រីគួរគប្បីផ្ញើរសំណើសង្ខេបឱ្យបានកាន់តែឆាប់កាន់តែប្រសើរ ដើម្បីឱ្យដំណើរការត្រួតពិនិត្យសំណើនោះអាចចាប់ផ្តើមប្រព្រឹត្តទៅបានឆាប់រហ័សដែរ ។ ការប្រកាសនេះគឺបើកទូលាយសំរាប់ប្រទេសឡាវ និងថៃ ប៉ុន្តែសំរាប់ប្រទេសកម្ពុជា និងវៀតណាមវិញគឺផ្តល់ឱកាសដល់អាទិភាពវិនិយោគរបស់ស៊ីអ៊ីភីអេហ្វទាំងឡាយណាដែលមិនទាន់បានឆ្លើយតបនាពេលកន្លងមក ។

ជាការចាំបាច់ណាស់ដែលអ្នកដាក់សំណើទាំងអស់ត្រូវអានយុទ្ធសាស្ត្រវិនិយោគ និងទិសដៅជាយុទ្ធសាស្ត្រសំរាប់តំបន់ឥណ្ឌូ-ភូមា ដែលមានអត្ថបទសង្ខេបជាភាសាអង់គ្លេស ខ្មែរ ឡាវ និង ថៃ (នឹងមានក្នុងពេលឆាប់ៗនេះ) និងមានឯកសារលំអិតជាភាសាវៀតណាមនៅក្នុងគេហទំព័រ http://www.birdlifeindochina.org/cepf/eligibility-criteria និងជាភាសាអង់គ្លេសនៅគេហទំព័រ http://cepf.net/Documents/final.indoburma_indochina.ep.pdf (ជាឯកសារ

PDF ទំហំ 2.5MB) ។

សំរាប់ប្រទេសឡាវ និងថៃ សំណើសង្ខេបអាចរៀបចំបានដោយឆ្លើយតបនិងទិសដៅយុទ្ធសាស្រ្តណាមួយក៏បាន ក្នុងចំណោមទិសដៅយុទ្ធសាស្រ្តទាំងបីខាងដើមដូចមានរៀបរាប់នៅក្នុងឯកសារស្តីពីប្រព័ន្ធអេកូស៊ីស្ទែម ។ សំរាប់ប្រទេសកម្ពុជា និងវៀតណាម សំណើសង្ខេបត្រូវបានលើកទឹកចិត្តឱ្យបំពេញនូវចន្លោះប្រហោងនៃយុទ្ធសាស្រ្តវិនិយោគរបស់ស៊ីអ៊ីភីអេហ្វដូចខាងក្រោមនេះ :

---

### ***១.១ ធ្វើអត្តសញ្ញាណកម្ម និងសង្រ្គោះដល់ពពួកសត្វសំខាន់ៗដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកចំនួន ៦៧ ប្រភេទពីការធ្វើអាជីវកម្មហួសកំរិត និងជំនួញខុសច្បាប់***

ប្រភេទសត្វជាអាទិភាពដែលទាក់ទាញការផ្តល់ថវិកាពីស៊ីអ៊ីភីអេហ្វលើកនេះរួមមាន : ក្របីព្រៃ (Wild Water Buffalo *Bubalus bubalis*), ខ្លាឡើងមាស (Asian Golden Cat *Catopuma temminckii*), រមាំង (Eld's Deer *Cervus eldii*), ខ្លាពពក (Clouded Leopard *Neofelis nebulosa*), ខ្លាភ្លើថ្មកែវ (Marbled Cat *Pardofelis marmorata*), សៅឡា (Saola *Pseudoryx nghetinhensis*), ស្វា Delacour's Leaf Monkey *Trachypithecus delacouri*, ខ្លាឃ្មុំធំ (Asian Black Bear *Ursus thibetanus*), ទាព្រៃស្លាបស (White-winged Duck *Cairina scutulata*), ខ្វែក (White-eared Night-heron *Gorsachius* magnificus), ក្រៀល (Sarus Crane *Grus antigone*), ពពូលទឹក (Masked Finfoot *Heliopais personata*), ក្ងោក (Green Peafowl *Pavo muticus*), ត្រយ៉ងចំកំកស (White-shouldered Ibis *Pseudibis davisoni*), ត្រយ៉ងយក្ស (Giant Ibis *Thaumatibis gigantea*), ក្រពើត្រី (Siamese Crocodile *Crocodylus siamensis*), អណ្តើកសោមទ្រនុងបី (Black-breasted Leaf Turtle *Geoemyda spengleri*), អណ្តើកសោមបន្លាភ្លៅ (Asian Giant Tortoise *Manouria emys*), អណ្តើកតឹកកាល់កលឿង (Asian Yellow Pond Turtle *Mauremys mutica*), ត្រីបបែល Mekong Freshwater Stingray *Dasyatis laosensis*, ត្រីបបែល Marbled Freshwater Stingray *Himantura oxyrhynchus*, ត្រីរាជ (Giant Catfish *Pangasianodon gigas*), ត្រីថ្ក (Freshwater Sawfish *Pristis microdon*), ត្រីត្រសក (Jullien's Golden Carp *Probarbus jullieni*), ត្រីក្បក (Laotian Shad *Tenualosa thibaudeaui*) ។

### ***១.២ អនុវត្តយុទ្ធនាការផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ ដើម្បីជួយពង្រឹងការអនុវត្តគោលនយោបាយដែលមានស្រាប់ស្តីពីអាជីវកម្មសត្វព្រៃ និងចូលរួមកាត់បន្ថយតំរូវការរបស់អ្នកប្រើប្រាស់លើពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកទាំង ៦៧ ប្រភេទ និងផលិតផលទាំងឡាយដែលផលិតចេញពីពួកវា ។***

គំរោងទាំងឡាយណាដែលឆ្លើយតបដោយផ្ទាល់ទៅនិងយុទ្ធសាស្រ្តវិនិយោគនេះត្រូវបានលើកទឹកចិត្ត ។

### ***១.៥ ធ្វើការស្រាវជ្រាវលើប្រភេទសត្វទាំង ១២ប្រភេទ (ថនិកសត្វ, សត្វស្លាប និងសត្វ ល្មូន) ដើម្បីធ្វើបច្ចុប្បន្នភាពនូវ***

***ពតិមានស្ដីពីស្ថានភាព និងរបាយរបស់ពួកវា ។***

ប្រភេទសត្វជាអាទិភាពសំរាប់ស៊ីអ៊ីភីអេហ្វដែលមិនទាន់មានគំរោងណាសិក្សាស្រាវជ្រាវកន្លងមករួមមានដូចជា : គោព្រៃ (Kouprey *Bos sauveli*), សំពោចភេ (Otter Civet *Cynogale bennettii*), កំពឹងដូងធ្មេញតូច (Small-toothed Mole *Euroscaptor* parvidens), ប្រចៀវច្រមុះសំប៉ែតវៀតណាម (Vietnam Leaf-nosed Bat *Paracoelops megalotis*), Chapa Pygmy Dormouse *Typhlomys chapaensis,* អណ្ដើកកក្រហម (Red-necked Pond Turtle *Chinemys nigricans)*, និង អណ្ដើកអាណាម (Vietnamese Pond Turtle *Mauremys annamensis*) ។

***១.៦ បោះពុម្ពឯកសារស្ដីពីពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកជាភាសាជាតិ ។***

គំរោងទាំងឡាយណាដែលឆ្លើយតបដោយផ្ទាល់ទៅនិងយុទ្ធសាស្ត្រវិនិយោគនេះត្រូវបានលើកទឹកចិត្ត ។

***២.១ បង្កើតវិធីសាស្ត្រគ្រប់គ្រងការអភិរក្សតាមរបៀបថ្មីមួយដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ និងការផ្ដួចផ្ដើមការពារក្នុងតំបន់ជីវចម្រុះសំខាន់ៗទាំង ២៨ កន្លែង***

តំបន់ជីវៈចម្រុះសំខាន់ជាអាទិភាពដែលទាក់ទាញការផ្ដល់ថវិកាពីស៊ីអ៊ីភីអេហ្វលើកនេះរួមមាន :

មេគង្គចាប់ពីក្រចេះទៅប្រទេសឡាវ, ទន្លេសេកុង, ទន្លេសេសាន ( តំបន់ទាំងអស់នេះនៅក្នុងប្រទេសកម្ពុជា)

បានប៊ុង, ប៊ិញ អាន, ចាំ ជូ, ដុង ហ្វុក, ណា ជី, ស៊ីង ឡុង, តាត កេ, ថាំង ហេន ឡេក ( តំបន់ទាំងអស់នេះនៅក្នុងប្រទេសវៀតណាម)

***២.២ បង្កើតនូវស្តង់ដារ និងកម្មវិធីជាលក្ខណៈតំបន់ដែលទប់ស្កាត់នូវរាល់ការធ្វើអាជីវកម្មហួសកំរិតលើជីវចម្រុះ និងអនុវត្តកម្មវិធីសាកល្បងនៅតំបន់ដែលបានជ្រើសរើស ។***

គំរោងទាំងឡាយណាដែលឆ្លើយតបដោយផ្ទាល់ទៅនិងយុទ្ធសាស្ត្រវិនិយោគនេះត្រូវបានលើកទឹកចិត្ត ។

***៣.១ គាំទ្រដល់ការខំប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការវិភាគនូវកម្មវិធី ផែនការ និងគោលនយោបាយអភិវឌ្ឍន៍នានាដោយវាយតំលៃពីផលប៉ះពាល់លើជីវចម្រុះ និងប្រព័ន្ធអេកូស៊ីស្ទែម ព្រមទាំងស្នើឡើងនូវជំរើសផែនការអភិវឌ្ឍន៍ថ្មី និងវិធានការសមស្របផ្សេងៗទៀតដើម្បីកាត់បន្ថយផលប៉ះពាល់នោះ ។***

គំរោងទាំងឡាយណាដែលឆ្លើយតបដោយផ្ទាល់ទៅនិងយុទ្ធសាស្ត្រវិនិយោគនេះត្រូវបានលើកទឹកចិត្ត ។

***៣.២ គាំទ្រដល់ការផ្ដួចផ្ដើមដែលបង្កើនការគាំទ្រដល់ការអភិរក្សជីវចម្រុះចេញពីគំរោង និងកម្មវិធីអភិវឌ្ឍន៍***

គំរោងទាំងឡាយណាដែលឆ្លើយតបដោយផ្ទាល់ទៅនិងយុទ្ធសាស្ត្រវិនិយោគនេះត្រូវបានលើកទឹកចិត្ត ។

-----------------------------------------------------------------------------------------------------------------

អង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ សហគ្រាសឯកជន និងស្ថាប័នសង្គមស៊ីវិលផ្សេងៗទៀតអាចដាក់សំណើរសុំថវិកានេះបាន ។ ស្ថាប័នទាំងនេះត្រូវតែមានគណនីផ្ទាល់ខ្លួននៅធនាគារ និងជាពិសេសមានសិទ្ធិគ្រប់គ្រាន់ក្រោមច្បាប់ជាតិក្នុងការទទួលអំណោយមនុស្សធម៌នេះបាន ។ សហគ្រាសឬស្ថាប័នរដ្ឋក៏អាចដាក់សំណើសុំថវិកានេះបានដែរ ប្រសិនបើអាចបង្ហាញថា ទីមួយស្ថាប័ននោះមានឯករាជ្យភាពស្របច្បាប់ ទីពីរមានសិទ្ធិក្នុងការដាក់សំណើសុំនិងទទួលបានមូលនិធិឯកជន និងទីបីមិនមានអភ័យឯកសិទ្ធិពិសេសណាមួយឡើយ ។

ទោះបីជាលក្ខណៈវិនិច្ឆ័យសំរាប់អ្នកដាក់សំណើត្រូវបានរៀបរាប់យ៉ាងទូលាយដូចខាងលើក៏ដោយ ក៏ការចង់បានដ៏ចំបងមួយគឺត្រូវបានប្រគល់អោយស្ថាប័នទាំងឡាយណាដែលអាចបង្ហាញយ៉ាងច្បាស់ថាខ្លួនជាអង្គការសង្គមស៊ីវិល និងអាចកសាងសមត្ថភាពសង្គមស៊ីវិលបានត្រូវបានលើកទឹកចិត្តជាពិសេសក្នុងការដាក់សំណើ ។ សំណើសុំថវិកាដែលរួមបញ្ចូលតួអង្គសង្គមស៊ីវិលទាំងឡាយណាដែលសមត្ថភាពនៅមានកំរិត (ពោលគឺមិនអាចដាក់សំណើសុំថវិកាបានដោយមិនអាចឆ្លើយតបនិងលក្ខណៈវិនិច្ឆ័យ ឬក៏គ្មានសមត្ថភាពក្នុងរៀបចំសំណើ ឧទាហរណ៍ដូចជាក្រុមសហគមន៍ជាដើម) ក៏ត្រូវបានលើកទឹកចិត្តផងដែរ ។ម្យ៉ាងទៀត ឯកត្តៈជន(បុគ្គលម្នាក់) ត្រូវបានលើកទឹកចិត្ត អោយធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងការរៀបចំសំណើជាជាងការដាក់សំណើសុំថវិកាជាលក្ខណៈបុគ្គល ។ ភាពមិនច្បាស់លាស់ពីលក្ខណៈវិនិច្ឆ័យក្នុងការដាក់សំណើសុំថវិកា ឬក៏ការអាចទទួលថវិកាបានអំពីមូលនិធិស៊ីអ៊ីភីអេហ្វ សូមទំនាក់ទំនងមកក្រុមការងារថ្នាក់តំបន់របស់អង្គការជីវិតសត្វស្លាបអន្តរជាតិតាមរយៈ cepf-rit@birdlife.org.vn ។

ជំនួយដែលផ្តល់អោយមិនអាចយកទៅប្រើប្រាស់សំរាប់ទិញដី ការផ្លាស់ប្តូរលំនៅរបស់ប្រជាពលរដ្ឋដោយគ្មានការស្ម័គ្រចិត្ត (រួមទាំងការដកហូតសិទ្ធិប្រើប្រាស់ដីធ្លីផងដែរ) ឬក៏សកម្មភាពទាំងឡាយដែលប៉ះពាល់ជាអវិជ្ជមានដល់ធនធានវប្បធម៌រូបវ័ន្ត រួមមានធនធានទាំងឡាយណាដែលមានសារៈសំខាន់ប្រជាជនក្នុងសហគមន៍ ។ ថវិកាដែលផ្តល់អោយនឹងមិនត្រូវប្រើសំរាប់សកម្មភាពទាំងឡាយដែលធ្វើអោយប៉ះដល់ផលប្រយោជន៍ជនជាតិភាគតិច ឬអនុវត្តសកម្មភាពនៅទីកន្លែងដែលជនជាតិភាគតិចទាំងនេះមិនផ្តល់ការគាំទ្រទូលំទូលាយ និងមិនត្រូវបានប្រើសំរាប់រុះរើ ឬធ្វើអោយខូចដល់ទ្រព្យសម្បត្តិវប្បធម៌រូបវ័ន្ត (ដែលមានដូចជាទីតាំងដែលមានតំលៃផ្នែកបុរាណវត្ថុវិទ្យា ផ្នែកបាសាណិភូតវិទ្យា ផ្នែកប្រវត្តិសាស្រ្ត សាសនា ឬក៏តំលៃដែលមានតែមួយក្នុងលោករបស់ធម្មជាតិ) ។ សំណើដែលស្នើមកត្រូវតែអនុលោមតាមគោលនយោបាយសង្គម និងការការពាររបស់ធនាគារពិភពលោកមាននៅក្នុងគេហទំព័រដូចខាងក្រោម :
http://go.worldbank.org/WTA1ODE7T0

មូលនិធិស៊ីអ៊ីភីអេហ្វ (CEPF) នឹងផ្តល់ទៅដល់ការអភិរក្សជីវចម្រុះតាមរយៈជំនួយពីរប្រភេទគឺ ជំនួយខ្នាតធំសំរាប់ថវិកាលើសពី ២០.០០០ ដុល្លារ និងជំនួយខ្នាតតូចសំរាប់ថវិកាត្រឹម ២០.០០០ ដុល្លារ ឬក៏តិចជាងនេះ ។ អង្គការឬស្ថាប័នណាចាប់អារម្មណ៍ត្រូវផ្ញើរសំណើសង្ខេបមក ។ សំណើសង្ខេបសំរាប់ជំនួយខ្នាតតូចអាចរៀបចំជាភាសាជាតិនិមួយៗបាន ដែលបច្ចុប្បន្នរួមមានភាសាខ្មែរ ឡាវ និងវៀតណាម ។ ទំរង់ ឬគំរូនៃសំណើសង្ខេបនេះមាននៅក្នុងគេហទំព័រ

http://birdlifeindochina.org/cepf/application-process ឬ http://cepf.net/Documents/cepf.loi.doc ។ ទំរង់សំណើសង្ខេប និងឯកសារស្តីពីទិសដៅយុទ្ធសាស្ត្រ និងអាទិភាពវិនិយោគដែលពាក់ព័ន្ធរបស់ស៊ីអ៊ីភីអេហ្វជាភាសាថៃ នឹងមាននៅក្នុងវេបសាយនាពេលឆាប់ៗនេះ ។ មុនពេលដាក់សំណើសង្ខេបជាផ្លូវការ អ្នកដាក់ពាក្យទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យធ្វើការពិភាក្សាជាមុនអំពីគោលគំនិតរបស់គំរោងដែលនឹងស្នើ ក៏ដូចជាលក្ខណៈវិនិច្ឆ័យដែលអាចដាក់សំណើបានជាមួយក្រុមការងារថ្នាក់តំបន់របស់អង្គការជីវិតសត្វស្លាបអន្តរជាតិតាមរយៈអ៊ីម៉ែល cepf-rit@birdlife.org.vn ។

**សំរាប់គំរោងដែលស្នើសុំថវិកាលើសពី ២០.000 ដុល្លារ** នៅពេលដែលសំណើសង្ខេបត្រូវបានរៀបចំរួចរាល់ហើយ សូមផ្ញើរអ៊ីម៉េលទៅ cepfgrants@conservation.org ដោយត្រូវភ្ជាប់សំណើសង្ខេបដែលបំពេញរួចនោះមកជាមួយ ។ លោក-លោកស្រីនឹងទទួលបានការជូនដំណឹងពីការទទួលបានសំណើ ហើយសំណើនេះនឹងត្រូវបញ្ជូនទៅក្រុមការងារដែលទទួលខុសត្រូវលើរឿងនេះ ។ លោក-លោកស្រីនឹងត្រូវគេទំនាក់ទំនងប្រាប់ពីជំហានដែលត្រូវធ្វើបន្តបន្ទាប់ទៀត ។ ចំពោះភាពមន្ទិលសង្ស័យ និងចំងល់ផ្សេងៗនៅក្នុងអំឡុងពេលនេះ លោក-លោកស្រីអាចសាកសួរបានតាមរយៈអ៊ីម៉ែលទៅកាន់ cepfgrants@conservation.org ។

**សំរាប់សំណើដែលត្រូវការថវិកា ២០.000ដុល្លារ ឬតិចជាងនេះ** នៅពេលដែលសំណើសង្ខេបត្រូវបានរៀបចំរួចរាល់ហើយ សូមផ្ញើរអ៊ីម៉េលទៅ cepf-rit@birdlife.org.vn ដោយត្រូវភ្ជាប់សំណើសង្ខេបដែលបំពេញរួចនោះមកជាមួយ ។ លោក-លោកស្រីនឹងទទួលបានការជូនដំណឹងពីការទទួលបានសំណើ ហើយសំណើនេះនឹងត្រូវបញ្ជូនទៅក្រុមការងារដែលទទួលខុសត្រូវលើរឿងនេះ ។ លោក-លោកស្រីនឹងត្រូវគេទំនាក់ទំនងប្រាប់ពីជំហានដែលត្រូវធ្វើបន្តបន្ទាប់ទៀត ។ រាល់សំណួរ និងចំងល់ផ្សេងៗនៅក្នុងអំឡុងពេលនេះ លោក-លោកស្រីអាចសាកសួរបានតាមរយៈអ៊ីម៉ែលទៅកាន់ cepf-rit@birdlife.org.vn ។

សូមបញ្ជាក់ថា ការផ្ញើរសំណើសង្ខេបតាមរយៈអ៊ីម៉េល ឬសារអេឡិចត្រូនិចត្រូវបានលើកទឹកចិត្ត ។

សំរាប់ព័ត៌មានលំអិតបន្ថែមទៀត សូមទំនាក់ទំនងមក :

ក្រុមការងារប្រចាំតំបន់របស់ស៊ីអ៊ីភីអេហ្វ (CEPF-RIT), អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំតំបន់ឥណ្ឌូចិន,
ផ្ទះលេខ N6/2+3, Lane 25, ផ្លូវឡាំងហា, ហាណូយ, វៀតណាម
អ៊ីម៉េល: cepf-rit@birdlife.org.vn គេហទំព័រ: www.birdlifeindochina.org/cepf
ទូរស័ព្ទ: +៨៤ (0)៤ ៣៥១៤ ៨៩0៤ Ext. ២៨ ហ្វាក់: +៨៤ (0)៤ ៣៥១៤ ៨៩២១